THE SCHOOL DISTRICT OF PHILADELPHIA

# ការណែនាំអំពីតម្រូវការនៃការចាក់ថ្នាំបង្ការរោគ



## តើកូនរបស់លោកអ្នកត្រៀមខ្លួនសម្រាប់ចូលរៀនហើយឬនៅ?

កូនរបស់លោកអ្នកត្រូវតែចាក់ថ្នាំបង្ការរោគរបស់ពួកគេឱ្យគ្រប់ចំនួន ដើម្បីចូលរៀននៅសាលាក្នុងទីក្រុងហ្វីឡាដែលហ្វ្យ៉ា។ សួរវេជ្ជបណ្ឌិតរបស់លោកអ្នក ដើម្បីប្រាកដថាកូនរបស់លោកអ្នកមានការចាក់ថ្នាំបង្ការរោគដូចខាងក្រោមសម្រាប់កម្រិតថ្នាក់របស់ពួកគេ។

## ការចាក់ថ្នាំបង្ការរោគដែលត្រូវការ

### សម្រាប់ការចូលរៀនគ្រប់ថ្នាក់ (មត្តេយ្យ - ទី ១២)

- *ខាន់ស្លាក់ តេតាណូស និង ក្អកមាន់ (DTap) ៥ ដង
- **ជំងឺស្វិតដៃជើង (IPV) ៤ ដង
- កញ្ជ្រឹល ស្រឡទែន និង ស្អូច (MMR) ២ ដង
- ជំងឺរលាកថ្លើមប្រភេទ B (HepB) ៣ ដង
- អុតតូច (VZV) ២ ដង

### សម្រាប់ការចូលរៀនថ្នាក់ទី ៧

- តេតាណូស ខាន់ស្លាក់ និង ក្អកមាន់ (Tdap) ១ ដង
- រោគរលាកស្រោមខួរ (MCV4) ១ ដង

### សម្រាប់ការចូលរៀនថ្នាក់ទី ១២

- ***រោគរលាកស្រោមខួរ (MCV4) ២ ដង

*DTap - ដូសទីប្រាំគឺមិនចាំបាច់ទេ ប្រសិនបើ DTaP ទី ៤ ត្រូវបានផ្តល់ឱ្យក្រោយខួបកំណើតទី ៤

**Polio - មិនចាំបាច់ចាក់ថ្នាំលើកទីបួនទេ ប្រសិនបើ Polio ទី ៣ ត្រូវបានផ្តល់ឱ្យក្រោយខួបកំណើតទី ៤

***MCV4 - មិនចាំបាច់ចាក់ថ្នាំទីពីរទេ ប្រសិនបើ MCV4 ទី ១ ត្រូវបានផ្តល់ឱ្យក្រោយខួបកំណើតទី ១៦

## អ្វីៗដែលត្រូវដឹង

- ត្រូវផ្តល់ភស្តុតាងនៃការចាក់ថ្នាំបង្ការរោគ ការបញ្ជាក់អំពីវេជ្ជសាស្ត្រ ឬលិខិតលើកលែងដល់យសាលារបស់សិស្សលោកអ្នក មិនឱ្យហួសថ្ងៃចូលរៀនដំបូង។ ការលើកលែងរួមមាន៖ ហេតុផលអំពីវេជ្ជសាស្ត្រ ជំនឿសាសនា ឬ ទស្សន/សីលធម៌ ឬការជឿជាក់នៃសីលធម៌។ សិស្សដែលទទួលការលើកលែងនឹងមិនអាចចូលរៀនបានក្នុងអំឡុងពេលមានការឆ្លងជំងឺដែលអាចការពារដោយថ្នាំបង្ការរោគ។
- សិស្សដែលគ្មានភស្តុតាងនៃការចាក់ថ្នាំបង្ការរោគ ការបញ្ជាក់អំពីរវេជ្ជសាស្ត្រ ឬលិខិតលើកលែង នឹងមិនអាចចូលរៀនបានទេ។
- មាតាបិតា និងសិស្ស ត្រូវពិភាក្សាជាមួយវេជ្ជបណ្ឌិតរបស់ពួកគេអំពីវ៉ាក់សាំងដែលមានសារៈសំខាន់ ប៉ុន្តែមិនចាំបាច់សម្រាប់ការចូលរៀន ដូចជា វ៉ាក់សាំងការពាររោគផ្តាសាយ កូវីដ មេរោគ HPV និង រោគរលាកស្រោមខួរប្រភេទ B ។

## កុំរង់ចាំ... ណាត់ពេលជួប និងចាក់ថ្នាំបង្ការរោគ!

ដើម្បីជ្រាបព័ត៌មានបន្ថែមអំពីតម្រូវការនៃការចាក់ថ្នាំបង្ការរោគ ឬវិធីសុំការលើកលែង សូមទាក់ទងគិលានុបដ្ឋាយិកាសាលារបស់លោកអ្នក មើលគេហទំព័រ philasd.org/vax ឬទូរស័ព្ទទៅលេខ (215) 400-5VAX ។ ការចាក់ថ្នាំបង្ការរោគក៏មាននៅតាមមណ្ឌលសុខភាពរបស់ទីក្រុងហ្វីឡាដែលហ្វ្យ៉ាផងដែរ។